មជ្ឈមណ្ឌលត្រួតពិនិត្យជាតិពុលផ្តល់នូវ
ដំបូន្មានដែលប្រកបដោយជំនាញតាមទូរស័ព្ទបានយ៉ាងរហ័ស។
យើងខ្ញុំអាចជួយអ្នក និងគ្រួសារអ្នក ដោយផ្តល់នូវសេវាកម្មសង្គ្រោះបន្ទាន់ពី
ការពុល និងឆ្លើយសំណួរនានាអំពីការបំពុល។

លោកអ្នកអាចហៅទូរស័ព្ទបាននៅពេលថ្ងៃ ឬ យប់ ៧ថ្ងៃ
ក្នុង ១សប្តាហ៍ និងថ្ងៃណាមួយក៏បានក្នុងឆ្នាំនេះ។ គិលានុបដ្ឋាយិកា
ឱសថការី វេជ្ជបណ្ឌិត និងអ្នកឯកទេស ខាងសារជាតិពុលដទៃទៀត
នឹងទទួលការហៅទូរស័ព្ទរបស់លោកអ្នក។

យើងខ្ញុំ អាចជួយលោកអ្នកបានជាង ១៥០ ភាសា
ឬបើលោកអ្នកទទួលការស្តាប់មិនសូវបានល្អ។

មានមជ្ឈមណ្ឌលត្រួតពិនិត្យជាតិពុលជាច្រើននៅទូទាំងប្រទេសរបស់យើង។
អ្នកអាចទំនាក់ទំនងទៅមជ្ឈមណ្ឌលត្រួតពិនិត្យជាតិពុលមួយកន្លែង
តាមរយៈការហៅទូរស័ព្ទទៅកាន់លេខ **១-៨០០-២២២- ១២២២**
ពីកន្លែងណាមួយនៅសហរដ្ឋអាមេរិក។




## ការព្យាបាលជាបឋមចំពោះការពុល

**ប្រសិនបើមនុស្សម្នាក់**

✓ ឈប់ដកដង្ហើម
✓ ភាពអស់កម្លាំង ឬ
✓ ប្រកាច់

**សូមហៅទូរស័ព្ទទៅកាន់លេខ ៩១១ ជាបន្ទាន់។**

**តើមានជាតិពុលនៅក្នុងភ្នែកឬ?**

លាងសំអាតភ្នែកដោយប្រើទឹកម៉ាស៊ីន។
ហៅទូរស័ព្ទទៅមជ្ឈមណ្ឌលត្រួតពិនិត្យជាតិពុលតាមរយៈលេខ
១-៨០០-២២២-១២២២។

**មានជាតិពុលនៅលើ/ប្រឡាក់ស្បែកឬ?**

ដោះសំលៀកបំពាក់ដែលមានជាប់ប្រឡាក់ជាតិពុលនោះចេញ។
លាងសំអាតស្បែកដោយប្រើទឹកម៉ាស៊ីន។ ហៅទូរស័ព្ទទៅមជ្ឈមណ្ឌលត្រួតពិនិត្យជាតិពុលតាមរយៈលេខ ១-៨០០-២២២-១២២២។

**មានការដកដង្ហើមចូលជាតិពុលចូលក្នុងខ្លួនឬ?**

ចេញទៅស្រូបខ្យល់អាកាសបរិសុទ្ធភ្លាម។
ហៅទូរស័ព្ទទៅមជ្ឈមណ្ឌលពិនិត្យជាតិពុលតាមរយៈ លេខ ១-៨០០-២២២-១២២២។

**មានការលេបជាតិពុលចូលក្នុងខ្លួនឬ?**

ហៅទូរស័ព្ទទៅមជ្ឈមណ្ឌលពិនិត្យជាតិពុលតាមរយៈ លេខ ១-៨០០-២២២-១២២២។

**កុំព្យាយាម**ព្យាបាលនៅផ្ទះ ឬ ព្យាយាមធ្វើឱ្យនរណាម្នាក់ក្អួតចេញ។ ចូរហៅទូរស័ព្ទទៅមជ្ឈមណ្ឌលពិនិត្យជាតិពុលជាមុនសិន។

សំរាប់ព័ត៌មានបន្ថែម ចូរមើលវិបសាយ www.aappc.org
ឬហៅទូរស័ព្ទទៅមជ្ឈមណ្ឌលពិនិត្យជាតិពុលមូលដ្ឋានរបស់អ្នក។

រក្សាសិទ្ធិ ដោយសមាគមន៍មជ្ឈមណ្ឌលត្រួតពិនិត្យជាតិ ពុលអាមេរិកឆ្នាំ ២០១០

# មជ្ឈមណ្ឌល ជាតិពុល លោកអ្នក



ជារៀងរាល់ ៨ វិនាទី
មានអ្នកត្រូវការមជ្ឈមណ្ឌលត្រួតពិនិត្យជាតិពុល...

## តើអ្នកអាចជាមនុស្សបន្ទាប់ដែរឬទេ?

POISON Help
១-៨០០-២២២-១២២២

**ជំនួយឯកទេសឥតគិតថ្លៃ រហ័ស**
**២៤ ម៉ោង/ថ្ងៃ**
**៧ ថ្ងៃ/សប្តាហ៍**

# តើអ្នកដឹងឬទេ?

ជារឿយៗ យើងគិតអំពីកុមារដែលមានជាតិពុលក្នុងខ្លួន។ ប៉ុន្តែ មនុស្សភាគច្រើនដែលស្លាប់ ដោយជាតិពុល គឺជាមនុស្សពេញវ័យ! ការពុលគឺជាគ្រោះថ្នាក់មួយសំរាប់យើងទាំងអស់គ្នា។



ស្ទើរតែគ្រប់របស់ទាំងអស់អាចមានជាតិពុល ប្រសិនបើមានការប្រើប្រាស់វាខុសវិធីមិនត្រូវតាមបរិមាណមនុស្សឬប្រើខុសមនុស្ស។

**របស់មានជាតិពុល ឬ ពិសមួយចំនួន មានដូចជា:**

- ថ្នាំពេទ្យ (វេជ្ជបញ្ជា ឱសថលក់ដោយគ្រូពេទ្យផ្ទាល់ រុក្ខជាតិថ្នាំ) និងថ្នាំលក់នៅតាមផ្លូវ
- ផលិតផលប្រើប្រាស់នៅក្នុងផ្ទះអ្នក ដូចជា សាប៊ូកក់សក់ សាប៊ូធ្វើឱ្យស ថ្នាំសំលាប់សត្វល្អិត និង រុក្ខជាតិឥតប្រយោជន៍ ជាតិបន្ថយកំដៅ និង ប្រេងចង្កៀង
- សារធាតុគីមី នៅកន្លែងធ្វើការ
- ការខាំ និង ទិច
- ផ្សិត និង រុក្ខជាតិ
- ចំហាយឬផ្សែង និង ឧស្ម័ន

ការទទួលទានថ្នាំ ឬថ្នាំរបស់អ្នកដទៃក្នុងបរិមាណមិនត្រឹមត្រូវ ញ៉ាំសាប៊ូលាងចានថ្នាំសំអាតដោយអចេតនា ឬទទួលទានគ្រឿងស្រវឹងច្រើនពេក អាចធ្វើឱ្យពុលបាន។

# ហេតុអ្វីបានជាអ្នកគួរហៅទូរស័ព្ទ?

ការពុលអាចកើតមានចំពោះមនុស្សរាល់គ្នាបាន ហើយមជ្ឈមណ្ឌលត្រួតពិនិត្យជាតិពុល គឺសំរាប់មនុស្សគ្រប់ៗគ្នា។ ការហៅទូរស័ព្ទគឺមិនគិតថ្លៃ និងមានលក្ខណៈសម្ងាត់ផ្ទាល់ខ្លួន។

**យើងខ្ញុំជួយឱ្យអ្នកសន្សំសំចៃថវិកា និងពេលវេលាបាន:**

មានមនុ ស្សចំនួន ៧នាក់ ក្នុងចំណោម ១០ នាក់ ដែលហៅទូរស័ព្ទទៅមជ្ឈមណ្ឌលត្រួតពិនិត្យជាតិពុលដើម្បី សុំជំនួយតាមទូរស័ព្ទផ្ទាល់។ ពួកគេមិនចាំបាច់ទៅជួបវេជ្ជបណ្ឌិត ឬទៅមន្ទីរពេទ្យនោះទេ។

**វេជ្ជបណ្ឌិតរបស់អ្នកក៏ហៅទូរស័ព្ទទៅមជ្ឈមណ្ឌលត្រួតពិនិត្យជាតិពុលដែរ:**

នៅពេលវេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកាត្រូវការជំនួយព្យាបាលការពុល ពួកគេហៅទូរស័ព្ទទៅកាន់មជ្ឈមណ្ឌលត្រួតពិនិត្យជាតិពុលនៅមូលដ្ឋានរបស់ខ្លួន។

***ពួកយើងគឺជាអ្នកឯកទេស។***




# ការណែនាំប្រាប់ខ្លីៗអំពីការបង្ការការពុល

ប្រសិនបើអ្នកគិតថាមានមនុស្សម្នាក់ពុល សូមហៅទូរស័ព្ទទៅកាន់លេខ ១-៨០០-២២២-១២២២ ជាបន្ទាន់។ ជានិច្ចកាល ការពុលធ្ងន់ធ្ងរមិនមានសញ្ញាឱ្យដឹងជាមុនឡើយ។

- ទុកលេខ ១-៨០០-២២២-១២២២ ក្នុងទូរស័ព្ទដៃរបស់អ្នក និងនៅក្បែរទូរស័ព្ទនៅផ្ទះ
- ទុកដាក់ថ្នាំពេទ្យ និងផលិតផលប្រើប្រាស់ក្នុងផ្ទះក្នុងប្រអប់ដើម និងនៅកន្លែងផ្សេងពីកន្លែងទុកចំណីអាហារ
- ជានិច្ចកាល អានស្លាកសំគាល់ និងធ្វើតាមការណែនាំ
- ចាក់សោរទុកផលិតផលប្រើប្រាស់ក្នុងផ្ទះ និងថ្នាំ។ ទុកដាក់របស់ទាំងនោះឆ្ងាយពីដៃក្មេង។
- ទិញផលិតផលវេចខ្ចប់បានត្រឹមត្រូវដើម្បីជៀសវាងក្មេងលេង។ តែសូមចងចាំថា របស់ទាំងនោះមិនរួចពីដៃក្មេងទេ។
- កុំហៅថ្នាំថាជា "ស្ករគ្រាប់"។ ជាតិពុលអាចនឹងមើលទៅដូចអាហារ ឬភេសជ្ជៈ។ ចូរបង្រៀនកូនៗឱ្យសួរមនុស្សពេញវ័យ ឬ មនុស្សធំសិនមុននឹងញ៉ាំអ្វីមួយ។
- សិក្សាពីផលិតផល និងថ្នាំដែលក្មេងប្រើឱ្យ "លួតកំពស់"។ និយាយប្រាប់កូនៗទាំងតូចទាំងធំអំពីគ្រោះថ្នាក់ទាំងនេះ។
- ត្រូវមានឧបករណ៍ឱ្យសញ្ញាប្រាប់អំពីជាតិកាបូនម៉ូណូអុកស៊ីតនៅក្នុងផ្ទះ។



**ជំនួយឯកទេសឥតគិតថ្លៃ រហ័ស**
**២៤ ម៉ោង/ថ្ងៃ ៧ ថ្ងៃ/សប្តាហ៍**

# ១-៨០០-២២២-១២២២